**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៩៦៤ ព.ណ.[illegible]

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០២០

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ**

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយ ប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែតុលា ឆ្នាំ២០២០ នឹងត្រូវលក់ ៣.២០២រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៧៧៦រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែតុលា ឆ្នាំ២០២០** នឹងចុះមក ៣.០៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៦០០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) | |
|---|---|---|---|---|---|
| ១ | Average MOPS | | ០,២៩៣០ ដុល្លារ | | ០,២៧៥៥ ដុល្លារ |
| ២ | ពន្ធ៖ | | ០,១៧៨១ ដុល្លារ | | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | | ០,០០០០ ដុល្លារ | |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | | ០,០៤០០ ដុល្លារ | |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | | ០,០២៩៦ ដុល្លារ | |
| ៣ | PREMIUM | | ០,២០ ដុល្លារ | | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | | ០,០៦៧២ ដុល្លារ | | ០,០៥៧៥ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៧៣៨៣ ដុល្លារ | | ០,៦៣២៦ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | | ៣.០៣៣ រៀល | | ២.៥៩៩ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៧៤ ដុល្លារ | | ០,៦៣ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | | ៣.០៥០ រៀល | | ២.៦០០ រៀល |

សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ដែលស្មើនឹង៤.១០៨រៀល/ដុល្លារអាមេរិក

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៦ កញ្ញា ២០២០ | ៤៥,៥០ | ៤៣,៧៤ |
| ១៧ កញ្ញា ២០២០ | ៤៦,៤៥ | ៤៣,៥៧ |
| ១៨ កញ្ញា ២០២០ | ៤៨,៥៣ | ៤៥,៤៣ |
| ២១ កញ្ញា ២០២០ | ៤៦,៨៨ | ៤៤,៣១ |
| ២២ កញ្ញា ២០២០ | ៤៥,៨០ | ៤៣,៦៣ |
| ២៣ កញ្ញា ២០២០ | ៤៦,០៨ | ៤៣,២៤ |
| ២៤ កញ្ញា ២០២០ | ៤៥,៥៤ | ៤២,៨២ |
| ២៥ កញ្ញា ២០២០ | ៤៦,៩៤ | ៤៣,៨៨ |
| ២៨ កញ្ញា ២០២០ | ៤៧,៥០ | ៤៣,៦៣ |
| ២៩ កញ្ញា ២០២០ | ៤៧,៦២ | ៤៤,១៧ |
| ៣០ កញ្ញា ២០២០ | ៤៥,៦០ | ៤៣,៣៨ |
| មធ្យមភាគ ១១ថ្ងៃ | ៤៦,៥៨៥៥ | ៤៣,៨០០០ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,២៩៣០ | ០,២៧៥៥ |

### ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែកក្កដា ដល់ ០១ ខែតុលា ឆ្នាំ២០២០




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការជូនដំណឹងនេះ ។